ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១០៥/១៣-វ៉ៃ ហ៊ុល ហ្គាមេន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន វ៉ៃ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី**

អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១២ ៩៧៣ ៦៨៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ ៖

- លោក តេង ភាព ជំនួយការរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- **សម្ព័ន្ធសហជីពកម្ពុជា** (CATU)

- **សហជីពកម្ពុជានៃរោងចក្រកាត់ដេរ វ៉ៃ ហ៊ុល ហ្គាមេន**

អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៨៩ ៩៣០ ២០៤ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

១- លោក ឈុន សំអូន មន្ត្រីដោះស្រាយវិវាទសម្ព័ន្ធសហជីពកម្ពុជា (CATU)

២- លោក កុល គន មន្ត្រីសម្ព័ន្ធសហជីពកម្ពុជា (CATU)

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

| | |
|---|---|
| ៣- អ្នកស្រី ជា ស្រីពៅ | ប្រធានសហជីពកម្ពុជាប្រចាំក្រុមហ៊ុន វ៉ៃ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី |
| ៤- លោក តុន ជីវ៉ន | អនុប្រធានសហជីព កម្ពុជាប្រចាំក្រុមហ៊ុន វ៉ៃ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី |
| ៥- លោក សេម គុន្ធា | លេខាធិការសហជីព កម្ពុជាប្រចាំក្រុមហ៊ុន វ៉ៃ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ក្រុមហ៊ុនត្រូវទទួលយកអ្នកស្រី ជា ស្រីពៅ ជាប្រធានសហជីព, លោក តុន ជីវ័ន្ត ជាអនុប្រធានសហជីព និង លោក សេម គន្ធា ជាលេខាធិការសហជីពឱ្យចូលធ្វើការជាធម្មតាវិញ។ ក្រុមហ៊ុនមិនឯកភាព។

២- ភាគីកម្មករសុំឱ្យក្រុមហ៊ុនផ្តល់អាហារថ្ងៃត្រង់មួយពេល ឬលុយ ៤០០០ រៀល ក្នុងមួយថ្ងៃ តែក្រុមហ៊ុនមិនមានលទ្ធភាព។ ក្រុមហ៊ុនអាចផ្តល់ជូនតែ ១០០០ រៀល ក្នុងមួយថ្ងៃ។

៣- កម្មករសុំឱ្យក្រុមហ៊ុនរក្សាប្រាក់ទ្រទ្រង់សុខភាព ចំនួន ៥ ដុល្លារ នៅដដែល។ ក្រុមហ៊ុនមិនឯកភាព។

៤- បងប្អូនកម្មករទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់រង្វាន់ធ្វើការទៀងទាត់ ចំនួន ២០ ដុល្លារ ក្នុងមួយខែ ភាគីក្រុមហ៊ុនអាចផ្តល់ជូនតែ ១០ ដុល្លារ ក្នុងមួយខែ ស្របតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួមដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៣៦០/១៣ កប/កណ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលបានទទួលពាក្យបណ្តឹងរបស់ភាគីកម្មករនិយោជិត។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលបានចាត់មន្ត្រីជំនាញឱ្យធ្វើការផ្សះផ្សាវិវាទការងារនេះ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៤ ចំណុច លើការទាមទារចំនួន ០៥ ចំណុច។ ចំណុចមិនសះជាចំនួន ០៤ ចំណុចនេះត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ៣៦០/១៣ កប/កណ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ហើយលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៤ ចំណុចនេះ ដោយសវនាការ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០៤ ចំណុចនេះ បន្ថែមទៀត ដោយភាគីកម្មករនិយោជិតសម្រេចដកចំណុចវិវាទចំនួន ០៣ ចំណុច គឺចំណុចវិវាទទី២ ទី៣ និងទី៤។ ចំណែកឯចំណុចវិវាទមិនសះជាមានចំនួន ០១ ចំណុច គឺចំណុចវិវាទទី១ ។

ថ្វីត្បិតតែសម្ព័ន្ធសហជីពកម្ពុជា និងក្រុមហ៊ុន វ៉ៃ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី ជាភាគីហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ក៏ប៉ុន្តែ ដោយសារសហជីពកម្ពុជាប្រចាំក្រុមហ៊ុនមិនទាន់ទទួលឋានៈជាអង្គការវិជ្ជាជីវៈ ព្រោះមិនទាន់ទទួលបានបញ្ជិកាជាផ្លូវការនៅឡើយ ដូច្នេះ ការដែលសម្ព័ន្ធសហជីពកម្ពុជា យល់ព្រមតំណាងឱ្យកម្មករនិយោជិតនៅក្នុងសំណុំរឿងនេះ មិនអាចបកស្រាយថា គូភាគីនៃសំណុំរឿងនេះ គឺជាហត្ថលេខីនៃអនុស្សារណៈស្តីពីការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ បានឡើយ។ ដូចនេះ សេចក្តីបង្គាប់នៅក្នុងសំណុំរឿងនេះ ជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីឈ្មោះពាណិជ្ជកម្ម ក្រុមហ៊ុន វ៉ៃ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី លេខ ៥៧៨៥ ពណ.ចបព ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១។

២- លក្ខន្តិកៈរបស់ក្រុមហ៊ុន វើ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី បានតំកល់ទុកនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម លេខ ២៨៤/២០១១ ពណ.ចបព ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន វើ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី លេខ ៩១២ ក.ប.វ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២។

៤- ពាក្យសុំចូលបំរើការងារ, កិច្ចសន្យាការងារសាកល្បង, កិច្ចសន្យាការងារមានថេរវេលាកំណត់, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, រាយឈ្មោះសមាជិកក្នុងបន្ទុកគ្រួសារ, លិខិតជូនដំណឹងមិនបន្តកិច្ចសន្យា និង សក្ខីប័ត្របើកប្រាក់ របស់ឈ្មោះ តុន ជីវ័ន។

៥- ពាក្យសុំចូលបំរើការងារ, កិច្ចសន្យាការងារសាកល្បង, កិច្ចសន្យាការងារមានថេរវេលាកំណត់, លិខិតបញ្ជាក់ទីលំនៅ, សំបុត្របញ្ជាក់កំណើត, លិខិតជូនដំណឹងមិនបន្តកិច្ចសន្យា និង សក្ខីប័ត្របើកប្រាក់ របស់ឈ្មោះ ជា ស្រីពៅ។

៦- ពាក្យសុំចូលបំរើការងារ, កិច្ចសន្យាការងារសាកល្បង, កិច្ចសន្យាការងារមានថេរវេលាកំណត់, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, រាយឈ្មោះសមាជិកក្នុងបន្ទុកគ្រួសារ, លិខិតជូនដំណឹងមិនបន្តកិច្ចសន្យា និង សក្ខីប័ត្របើកប្រាក់ របស់ឈ្មោះ សេម គុន្ធា។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន វើ ហ៊ុល ហ្គាមេន ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣។

៨- លិខិតលេខ ០១៨ សសក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់សម្ព័ន្ធសហជីពកម្ពុជា គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ស្តីពីសំណើសុំជួយអន្តរាគមន៍រោងចក្រកាត់ដេរ វើ ហ៊ុល ហ្គាមេន ករណីរើសអើងសហជីព និងទាមទារលក្ខខណ្ឌការងារ។

៩- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន វើ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី ផ្ទេរសិទ្ធិជូន លោក តេង ភាព លេខ ១៥/១៣ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣។

១០- គំរូទំរង់ការវាយតំលៃលើការងាររបស់ប្រធានក្រុម របស់ក្រុមហ៊ុន វើ ហ៊ុល ហ្គាមេន (ខេមបូឌា) អ៊ិលធីឌី។

១១- សក្ខីប័ត្របើកប្រាក់ឈ្នួល បុគ្គលិក-កម្មករ របស់ឈ្មោះ សេម គុន្ធា, តុន ជីវ័ន, ជា ស្រីពៅ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ០១៨ សសក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់សម្ព័ន្ធសហជីពកម្ពុជា គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ស្តីពីសំណើសុំជួយអន្តរាគមន៍រោងចក្រកាត់ដេរ វើ ហ៊ុល ហ្គាមេន ករណីរើសអើងសហជីព និងទាមទារលក្ខខណ្ឌការងារ។

២- លិខិតលេខ ០១៦ សសក ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ របស់សម្ព័ន្ធសហជីពកម្ពុជា គោរពជូនលោកនាយករោងចក្រកាត់ដេរ វើ ហ៊ុល ហ្គាមេន ស្តីពីជូនដំណឹងអំពីថ្នាក់ដឹកនាំអាណត្តិទី១ សហជីព

កម្ពុជា នៃរោងចក្រកាត់ដេរ វ៉ៃ ហ៊ុល ហ្គាមេន ចំនួន ៣ រូប ។

៣- បង្កាន់ដៃទទួលសំណុំរឿងរបស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលពីសហជីពកម្ពុជានៃរោងចក្រកាត់ដេរ វ៉ៃ ហ៊ុល ហ្គាមេន ស្តីពីសុំចុះបញ្ជិកា ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ។

៤- កំណត់ហេតុស្តីពីការបង្កើតសហជីពកម្ពុជានៃរោងចក្រកាត់ដេរ វ៉ៃ ហ៊ុល ហ្គាមេន ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៣ ។

៥- កាតសំគាល់ខ្លួនរបស់ឈ្មោះ ជា ស្រីពៅ និងឈ្មោះ សេម គុន្ធា ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វ៉ៃ ហ៊ុល លេខ ៣៦០/១៣ កប/កណ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន វ៉ៃ ហ៊ុល ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៥៣៨ កប/អក/វក/លកអ. ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៥៣៩ កប/អក/វក/លកអ. ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទវិវាទអំពីសិទ្ធិ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៣ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន វ៉ៃ ហ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី ជាប្រភេទក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ដែលមានជួលកម្មករនិយោជិតសរុបប្រមាណ ១០២០ នាក់ ។
- នៅក្នុងក្រុមហ៊ុន មានការបោះឆ្នោតបង្កើតសហជីពមូលដ្ឋាន ដែលមានឈ្មោះសហជីពកម្ពុជា ប៉ុន្តែ សហជីពកំពុងរង់ចាំវិញ្ញាបនប័ត្រចុះបញ្ជិកាពីក្រសួងការងារ បន្ទាប់ពីការស្នើសុំចុះបញ្ជិកា ដោយមានបង្កាន់ដៃស្នើសុំចុះបញ្ជិកា នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ។ ក្នុងសវនាការ មានវត្តមានកម្មករនិយោជិតចំនួន ០៣ នាក់

គឺ (១) កម្មការិនី ជា ស្រីពៅ, (២) កម្មករ តុន ជីវ៉ន និង (៣) កម្មករ សេម គុន្ធា ។

**ចំណុចវិវាទ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយក (១)កម្មការិនី ជា ស្រីពៅ ជាប្រធានសហជីព, (២)កម្មករ តុន ជីវ៉ន ជាអនុប្រធានសហជីព និង (៣)កម្មករ សេម គុន្ធា ជាលេខាធិការសហជីព ឱ្យចូលធ្វើការ ជាធម្មតាវិញ***

- **(១)កម្មការិនី ជា ស្រីពៅ ៖**
  - កម្មការិនី ជា ស្រីពៅ មានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ ចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ក្នុងតួនាទីជាប្រធានក្រុម និងទទួលបានប្រាក់ឈ្នួលប្រចាំខែមេសា ឆ្នាំ២០១៣ ចំនួន ៩៤ ដុល្លារអាមេរិកក្នុងមួយខែ។ មុនក្លាយជាកម្មករពេញសិទ្ធិ គាត់បានចូលបម្រើការងារក្នុងក្រុមហ៊ុនក្រោមកិច្ចសន្យាសាកល្បងចាប់ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣ និងត្រូវបាននិយោជកផ្តាច់កិច្ចសន្យាការងារនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣។ គាត់ជាប់ឆ្នោតជាប្រធានសហជីពតាមរយៈការបោះឆ្នោតនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៣។
- **(២) កម្មករ តុន ជីវ៉ន ៖**
  - កម្មករ តុន ជីវ៉ន មានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ ចាប់ពីថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០១៣ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៣ ក្នុងតួនាទីជាកម្មករនិយោជិតផ្នែកដេរ និងទទួលបានប្រាក់ឈ្នួល ចំនួន ៩៤ ដុល្លារអាមេរិកក្នុងមួយខែ។ មុនក្លាយជាកម្មករពេញសិទ្ធិ គាត់បានចូលបម្រើការងារក្នុងក្រុមហ៊ុន ដែលជាប្រភេទកិច្ចសន្យាសាកល្បងចាប់ពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដល់ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ និងត្រូវបាននិយោជកផ្តាច់កិច្ចសន្យាការងារ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣។ គាត់ជាប់ឆ្នោត ជាអនុប្រធានសហជីពតាមរយៈការបោះឆ្នោតនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៣។
- **(៣)កម្មករ សេម គុន្ធា ៖**
  - កម្មករ សេម គុន្ធា មានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ ចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៣ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៣ ក្នុងតួនាទីជាជំនួយការផ្នែកបោកគត់ និងទទួលបានប្រាក់ឈ្នួលចំនួន ៩៤ ដុល្លារអាមេរិក ក្នុងមួយខែ។ មុនក្លាយជាកម្មករពេញសិទ្ធិ គាត់បានចូលបម្រើការងារក្នុងក្រុមហ៊ុនដែលជាប្រភេទកិច្ចសន្យាសាកល្បងចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៣ និងត្រូវបាននិយោជកផ្តាច់កិច្ចសន្យាការងារ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣។ គាត់ជាប់ឆ្នោត ជាលេខាសហជីពតាមរយៈការបោះឆ្នោតនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៣។

➢ **ព័ត៌មានទាក់ទងនឹងការបង្កើតសហជីពកម្ពុជា ៖**

- ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៣ សហជីពកម្ពុជាប្រចាំក្រុមហ៊ុន វ៉ៃ ហ៊្វិល ហ្គាមេន (ខេមបូឌា) អិលធីឌី បានរៀបចំបោះឆ្នោតបង្កើតសហជីព និងបានទទួលបង្កាន់ដៃសុំចុះបញ្ជិកាសហជីពពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ដែលមានកម្មការិនី ជា ស្រីពៅ ជាប់ជាប្រធានសហជីព, កម្មករ តុន ជីវ៉ន ជាប់ជាអនុប្រធានសហជីព និងកម្មករ សេម គុន្ធា ជាប់ជាលេខាសហជីព ។
- ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ សហជីពបានជូនដំណឹងពីសមាសភាពនៃថ្នាក់ដឹកនាំសហជីពកម្ពុជាទៅនិយោជកតាមរយៈលិខិតជូនដំណឹងលេខ ០១៦ សសក ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ ដោយមានសន្តិសុខចុះហត្ថលេខាទទួល និងត្រូវបានប្រធានរដ្ឋបាលទទួលលិខិតជូនដំណឹងនេះផងដែរ ។

➢ **អំណះអំណាងរបស់ភាគីនិយោជក និងភាគីកម្មករនិយោជិត ៖**

- ភាគីនិយោជកបានបញ្ជាក់ថា និយោជកពិតជាបានបញ្ឈប់ការងាររបស់កម្មករនិយោជិតទាំង ០៣ នាក់នេះមែន ព្រោះពួកគាត់ធ្វើការមិនល្អ ។ ភាគីនិយោជកបានបន្តទៀតថា និយោជកបានបញ្ឈប់ពួកគាត់ទាំង ០៣ នាក់នេះ ដោយយោងតាមការយោបល់និងវាយតម្លៃរបស់ប្រធានផ្នែក ។ ចំពោះការបញ្ឈប់កម្មករនិយោជិតទាំង ០៣ នាក់នេះ គឺមិនបានគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ ។
- ភាគីកម្មករនិយោជិតបានអះអាងថា ការបញ្ឈប់នេះមានការទាក់ទងនឹងការបង្កើតសហជីព និងមានការរើសអើងសហជីពនៅក្នុងក្រុមហ៊ុន ។ ការបញ្ឈប់កម្មករនិយោជិតទាំង ០៣ នាក់ គឺកើតឡើង បន្ទាប់ពីតំណាងសហជីពបានផ្ញើលិខិតជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំសហជីព ដែលជាប់ឆ្នោតនាថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៣ ទៅឱ្យនិយោជក ។ ភាគីកម្មករនិយោជិតបានបន្តទៀតថា ពួកគាត់ទាំង ០៣ នាក់នេះ មិនធ្លាប់ទទួលការព្រមានពីនិយោជក ឬមានកំហុសណាមួយក្នុងអំឡុងពេលធ្វើការងារកន្លងមកនោះទេ ។
- ភាគីកម្មករនិយោជិតបដិសេធចំពោះការលើកឡើងរបស់ភាគីនិយោជកដែលថា កម្មករនិយោជិតទាំង ០៣ នាក់ បានបំពេញការងារមិនល្អ ។ កម្មការិនី ជា ស្រីពៅ បានបញ្ជាក់នៅក្នុងសវនាការថា គាត់ធ្វើការបានល្អ ដូចនេះ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ គឺប្រធានផ្នែកបានតម្លើងឋានៈគាត់ពីកម្មករនិយោជិតដេរ ទៅប្រធានក្រុមដេរ ប៉ុន្តែ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣ និយោជកបានទម្លាក់តំណែងរបស់គាត់ពីប្រធានក្រុមដេរ ទៅជាកម្មករនិយោជិតដេរវិញ ។ គាត់បានបញ្ជាក់ទៀតថា ការទម្លាក់តំណែងរបស់គាត់នេះ គឺបន្ទាប់ពីនិយោជកបានដឹងថា គាត់ជាប់ជាប្រធានសហជីពកម្ពុជាប្រចាំក្រុមហ៊ុន ។
- ភាគីនិយោជកបានបន្ថែមទៀតថា រាល់ការបញ្ឈប់មុនដល់ថិរវេលាកំណត់នៃកិច្ចសន្យាកម្មករ

និយោជិតទាំង ០៣ នាក់ គឺនិយោជកនឹងផ្តល់ប្រាក់ឈ្នួល រហូតដល់ថ្ងៃកំណត់នៃកិច្ចសន្យា និង ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ប៉ុន្តែ កម្មករនិយោជិតទាំង ០៣ នាក់នេះ មិនទាន់បានទៅបើកប្រាក់ទាំងនេះទេ។

- រាល់ការបញ្ឈប់កម្មករនិយោជិតដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពទាំង ០៣ នាក់ គឺនិយោជកពុំបានការអនុញ្ញាតពីអធិការការងារទេ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយក (១)កម្មការិនី ជា ស្រីពៅ ជាប្រធានសហជីព, (២)កម្មករ តុន ជីវ៉ែន ជាអនុប្រធានសហជីព និង (៣)កម្មករ សេម គុន្ធា ជាលេខាធិការសហជីព ឱ្យចូលធ្វើការជាធម្មតាវិញ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកបានបញ្ឈប់កម្មករនិយោជិត ដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពទាំង ០៣ នាក់ ត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ស្តីពីការងារដែរ ឬទេ?

ប្រការ៣ កថាខ័ណ្ឌទី៣ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចែងថា “*កម្មករនិយោជិតទាំងអស់ដែលជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទទួលបានទូវការការពារចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ។ ការការពារនេះ មានរយៈពេល ៤៥ ថ្ងៃ មុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះមិនត្រូវបានជាប់ឆ្នោត*” ។

ផ្អែកលើខ្លឹមសារនៃប្រការ ៣ កថាខ័ណ្ឌទី៣ នៃប្រកាសលេខ ៣០៥ សកបយ ខាងលើមានន័យថា ការការពារពិសេសនេះ គឺមានរយៈពេលកំណត់ចំពោះបេក្ខជន ដែលមិនត្រូវបានជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីព។ ពោលគឺការការពារនេះមាន រយៈពេល ៤៥ថ្ងៃ មុនការបោះឆ្នោត នឹងត្រូវបញ្ចប់ក្នុងរយៈពេល៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ប៉ុន្តែ ចំពោះបេក្ខជនឈរឈ្មោះ ដែលបានជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីព យោងតាមប្រការ៣ កថាខ័ណ្ឌ៣ នៃប្រកាស ៣០៥ ខាងលើ ពុំបានកំណត់រយៈពេលជាក់លាក់ណាមួយសម្រាប់ការការពារ ដែលនឹងត្រូវបញ្ចប់ទេ។

នៅក្នុងសំណុំរឿង ៤០/១០-ម៉េង យ៉ាន់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា “*នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំគាល់ឃើញថា ការការពារចំពោះបេក្ខជនដែលជាប់ឆ្នោតនេះ មិនអាចបន្តបានរហូតទេ។ ប៉ុន្តែ ការការពារគួរតែទទួលបានយ៉ាងហោចណាស់ ចំនួន៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ឬអាចបន្តក្នុងរយៈពេលមួយសមរម្យ ដូចជាបន្តការពាររហូតដល់ថ្ងៃ ដែលពួកគាត់ដាក់ពាក្យសុំចុះបញ្ជិកាសហជីព*”។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយខាងលើនេះដែរ។

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា បន្ទាប់ពីមានការរៀបចំបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពកម្ពុជា នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៣ និយោជកបានបញ្ឈប់ កម្មករ តុន ជីវ៉ែន និងកម្មករ សេម គុន្ធា នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣ និងកម្មការិនី ជា ស្រីពៅ នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៣ មុន

កាលកំណត់កិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលារបស់ពួកគាត់។ ក្រោយមកសហជីពបានធ្វើការស្នើសុំចុះបញ្ជិកា ដោយបានទទួលបង្កាន់ដៃសុំចុះបញ្ជិកាសហជីព ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ដែលមានកម្មការិនី ជា ស្រីពៅ ជាប់ជាប្រធានសហជីព, កម្មករ តុន ជីវ័ន ជាប់ជាអនុប្រធានសហជីព និងកម្មករ សេម គុន្ធា ជាប់ជាលេខាធិការសហជីព។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបានបញ្ឈប់ពួកគាត់ដែលបានជាប់ឆ្នោត នៅក្នុងអំឡុងពេល ៤៥ ថ្ងៃ ក្រោយថ្ងៃបោះឆ្នោត ដែលពួកគាត់ទទួលបានការការពារពិសេសពីការបញ្ឈប់។

ទន្ទឹមនឹងនេះដែរ ប្រការ ៣ កថាខ័ណ្ឌ៣ ខាងលើ បានចែងបន្តទៀតថា *"ការទទួលបានការការពារពិសេសនេះ សហជីពត្រូវជូនដំណឹងទៅនិយោជកអំពីបេក្ខភាពនេះ តាមគ្រប់មធ្យោបាយទាំងអស់ ដែលទុកជាបានការ"*។

យោងតាមអង្គហេតុខាងលើ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ សហជីពបានជូនដំណឹងពីសមាសភាពនៃថ្នាក់ដឹកនាំសហជីពកម្ពុជាប្រចាំក្រុមហ៊ុន តាមរយៈលិខិតលេខ ០១៦ សសក ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ ទៅនិយោជក ដោយមានសន្តិសុខចុះហត្ថលេខាទទួល និងបានប្រគល់លិខិតជូនដំណឹងនេះឱ្យប្រធានរដ្ឋបាលផងដែរ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីពពិតជាបានជូនដំណឹងទៅនិយោជកអំពីបេក្ខភាព ថ្នាក់ដឹកនាំសហជីព តាមគ្រប់មធ្យោបាយដែលទុកជាបានការ ហើយនិយោជកបានដឹងពីសមាសភាពរបស់ពួកគាត់ ដែលទើបនឹងជាប់ឆ្នោតតាមរយៈការជូនដំណឹងពីតំណាងសហជីព នាថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ ។

មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាមួយពីការងាររបស់ខ្លួនអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ...អធិការការងារ ដែលបានទទួលពាក្យបណ្តឹងសុំបញ្ឈប់កម្មករនិយោជិត ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនដល់និយោជក ដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់...ក្នុងរយៈពេលមួយខែយ៉ាងយូរក្រោយពីទទួលពាក្យបណ្តឹង។..."*។

ផ្អែកលើខ្លឹមសារនៃមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រាល់ការបញ្ឈប់កម្មករនិយោជិតដែលទទួលបានការការពារ និយោជកត្រូវមានការអនុញ្ញាតពីអធិការការងារ និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ។ មានន័យថា អធិការការងារមានតួនាទីពិចារណា ស្រាវជ្រាវ និងសម្រេចផ្តល់ការអនុញ្ញាត ឬបដិសេធចំពោះសំណើរបស់និយោជក ដែលសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីពក្នុងរយៈពេលមួយខែយ៉ាងយូរក្រោយទទួលពាក្យបណ្តឹង។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១៤៩/០៨-ខេមបូ ហាន់ស៊ែ ហេតុផលចំណុចទី ១, លេខ ១៧៥/០៩-អាជ្ញាធរអប្សរា ហេតុផលចំណុចវិវាទទី២ និងលេខ ១២/១២-ហ្វៃ យ៉ាង (ខេមបូឌា) ហេតុផលចំណុចវិវាទទី១៣* )។

ក្នុងសំណុំរឿងនេះ និយោជកបានដឹងពីការជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីព របស់កម្មករនិយោជិតទាំង ០៣ រូបនេះ(កម្មការិនី ជា ស្រីពៅ, កម្មករ តុន ជីវ័ន និង កម្មករ សេម គុន្ធា) តាមរយៈលិខិតលេខ ០១៦ សសក ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ របស់សម្ព័ន្ធសហជីពកម្ពុជា ដែលបានដាក់ជូនភាគីនិយោជកដោយមាន សន្តិសុខបានចុះហត្ថលេខាទទួលនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣។ នៅសវនាការ ភាគីនិយោជកក៏បានអះអាងថា នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ ដដែល ប្រធានរដ្ឋបាលបានទទួលលិខិតជូនដំណឹងអំពីសមាសភាពបេក្ខជនជាប់ឆ្នោតជា

ថ្នាក់ដឹកនាំសហជីពនេះផងដែរ ។ ប៉ុន្តែនិយោជក បានចាត់វិធានការដាក់វិន័យបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិត ទាំង ០៣ រូប ដែលជាថ្នាក់ដឹកនាំសហជីព ដោយមិនបានសុំការអនុញ្ញាតពីអធិការការងារទេ ។ តាមន័យនេះ និយោជកមិនបានគោរពទៅតាមនិតិវិធីនៃការបញ្ឈប់កម្មករនិយោជិត ដែលបានទទួលការការពារពិសេសពីការបញ្ឈប់នោះឡើយ ។

ហេតុដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បង្គាប់ឱ្យនិយោជកទទួលយកកម្មការិនី ជា ស្រីពៅ, កម្មករ តុន ជីវ៉ន និង កម្មករ សេម គុន្ធា ចូលធ្វើការជាធម្មតាវិញ ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ ៖**

បង្គាប់ឱ្យនិយោជកទទួលយកកម្មការិនី ជា ស្រីពៅ, កម្មករ តុន ជីវ៉ន និងកម្មករ សេម គុន្ធា ចូលធ្វើការជាធម្មតាវិញ ។

**ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា ៖ ----------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា ៖ ----------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល ៖**

ឈ្មោះ ៖ **គង់ ផល្លៈ**

ហត្ថលេខា ៖ ----------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL